**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០៥.០៩២/០៩ គ.ជ.ប.អគ្គ.ពស**

រាជធានីភ្នំពេញ ថ្ងៃទី 17 ខែឧសភា ឆ្នាំ២០០៩

# បណ្តឹងសរុប ចំនួន ១៣ ត្រូវបានប្តឹងនៅ គធ/ខប ក្នុងដំណាក់កាលឃោសនាបោះឆ្នោត

ក្នុងដំណាក់កាលឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ រយៈពេល ១៥ថ្ងៃ (ពីថ្ងៃទី០១ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០០៩) នេះ គណៈកម្មការរាជធានី/ខេត្តរៀបចំការបោះឆ្នោត (គធ/ខប) ទទួលបានពាក្យបណ្តឹងសរុប ចំនួន ១៣ ដែលបណ្តឹងទាំងនេះប្តឹងមកពីតំណាងគណបក្ស សម រង្ស៊ី ។

ពាក្យបណ្តឹងទាំង ១៣ នេះ រួមមាននៅ គធ/ខប កំពង់ធំ ០២បណ្តឹង គធ/ខប រាជធានីភ្នំពេញ ០៣បណ្តឹង គធ/ខប ស្ទឹងត្រែង ០១បណ្តឹង គធ/ខប បាត់ដំបង ០៣បណ្តឹង គធ/ខប សៀមរាប ០១បណ្តឹង គធ/ខប ព្រៃវែង ០១បណ្តឹង និងនៅ គធ/ខប បន្ទាយមានជ័យ ០២បណ្តឹង ។

បណ្តឹងទាំងអស់នេះប្តឹងពីបទ ៖

- លួងលោម បញ្ចុះបញ្ចូល ទិញសន្លឹកឆ្នោត ចំនួន ០៩បណ្តឹង
- យកអាគាររដ្ឋឃោសនាបោះឆ្នោត ចំនួន ០១បណ្តឹង
- ដកហូតមិនឱ្យមានសិទ្ធិបោះឆ្នោត ចំនួន ០១បណ្តឹង
- សុំផ្តល់សុពលភាពឱ្យមានសិទ្ធិបោះឆ្នោត ចំនួន ០១បណ្តឹង
- រារាំងបេក្ខជន និងអ្នកគាំទ្រឃោសនាបោះឆ្នោត ចំនួន ០១បណ្តឹង ។

បណ្តឹងទាំងនោះត្រូវបានធ្វើការដោះស្រាយដោយ គធ/ខប ដូចខាងក្រោម ៖

- បើកសវនាការជាសាធារណៈ រួចបដិសេធ ចំនួន ០៣បណ្តឹង
- បដិសេធតាមរយៈលិខិតឆ្លើយតប ចំនួន ០២បណ្តឹង
- ចារបដិសេធលើពាក្យបណ្តឹង (បណ្តឹងហួសពេលកំណត់) ចំនួន ០៣បណ្តឹង
- ធ្វើការផ្សះផ្សាសះជា ចំនួន ០១បណ្តឹង
- កំពុងដោះស្រាយ ចំនួន ០៤បណ្តឹង ។

ព័ត៌មានបន្ថែមសូមទំនាក់ទំនងទូរស័ព្ទលេខ: ០២៣ ២១៤ ៣៧៤ / ០១២ ៨៥៥ ០១៨ E-mail: necinfo@forum.org.kh, Website: www.necelect.org.kh